


តោះ!ពិនិត្យមើលកាលវិភាគនៃការប្រលង។

សូមអានលើទំព័រទី4នៃសៀវភៅណែនាំ។




មានការប្រលងជ្រើសរើសទូទៅនៅខែកុម្ភះ។

ការប្រលងជ្រើសរើសទូទៅនឹងធ្វើឡើងនៅគ្រប់វិទ្យាលយ័រដ្ឋ។

អាចប្រលងចូលបានតែ1វិទ្យាលយ័។

ការប្រលងជ្រើសរើសទូទៅនឹងការជ្រើសរើសពិសេសនឹងធ្វើឡើងក្នុងពេលតែមួយ

ដាច់ខាតត្រូវដាក់ពាក្យនឹងឯកសារមុនពេលប្រលង។




ការប្រលងជ្រើសរើសទូទៅមានប្រលងចំណេះដឹងនឹងមានការជួបសម្ភាសន៍។

វិទ្យាល័យខ្លះមានជ្រើសរើសដោយពិនិត្យលើលក្ខណះពិសេសជាដើម។




ករណីប្រលងចូលវិទ្យាល័យឯកជន។

អាចជ្រើសរើសយកវិទ្យាល័យឯកជន1ដែលចង់ប្រលង ហៅថា「សេនហ្គាន់(せんがん)」

មានក្បួនប្រលងដោយជ្រើសរើសយកវិទ្យាល័យឯកជន1ដែលងាយចូលនឹងវិទ្យាល័យរដ្ឋ1ដែលសិស្សចង់ចូលហៅថា「ហេយហ្គាន់(へいがん)」

បើប្រលងហេយហ្គាន់ហើយជាប់ទាំងវិទ្យាល័យរដ្ឋនឹងឯកជន អាចជ្រើសរើសយកវិទ្យាល័យរដ្ឋដោយទាត់ចោលវិទ្យាល័យឯកជនបាន។

ប្រសិនបើប្រលងជាប់តែវិទ្យាល័យឯកជន ចាំបាច់ត្រូវតែចូលរៀននៅវិទ្យាល័យនោះ។បើមិនចូលទេ ក៏មិនអាចប្រលងចូលវិទ្យាល័យទៀតដែរ។

ការចូលរៀនវិទ្យាល័យឯកជន ត្រូវគិតគូអំពីថ្លៃសាលា។សូមពិភាក្សាជាមួយអាណាព្យាបាលអោយបានច្បាស់។




ប្រសិនបើប្រលងទូទៅធ្លាក់ ឬមួយក៏ប្រលងចូលវិទ្យាលយ័ឯកជនក៏ធ្លាក់ នៅខែមិនាមានការជ្រើសរើសចូលវិទ្យាលយ័ក្រៅម៉ោងឬរៀនតាមប្រពន្ធ័ប្រៃសណីយ។ ការប្រលងនេះគឺសម្រាប់តែការរៀនតាមប្រពន្ធ័ក្រៅម៉ោងឬរៀនតាមប្រពន្ធ័ប្រៃសណីយ។

មានវិទ្យាលយ័បង្រៀនតាមប្រពន្ធ័ក្រៅម៉ោងខ្លះមិនមានការប្រលងទេ។

សូមប្រុងប្រយត្ន័ចំពោះសិស្សដែលបានប្រលងទូទៅហើយបានជាប់វិទ្យាលយ័ឯកជននោះមិនអាចប្រលងបានទេ។

ខ្លឹមសារនៃការប្រលងគឺដូចទៅនឹងការប្រលងទូទៅ។




បើប្រលងចូលវិទ្យាល័យក្រៅម៉ោងឬរៀនតាមប្រពន្ធ័ប្រៃសណីយធ្លាក់មានសាលាខ្លះ

ធ្វើការជ្រើសរើសជាលើកទី2

សូមកុំបោះបង់រហូតដល់ទីបញ្ចប់!